ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៧ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម តាមរយៈការប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដើម្បី៖

- ទប់ស្កាត់និងកាត់បន្ថយការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមក្លែងក្លាយ ឧបករណ៍ដែលជាផលចោរកម្ម និងឧបករណ៍ដែលនាំចូលខុសច្បាប់
- ការពារសុខភាព សុវត្ថិភាព និងសិទ្ធិអ្នកប្រើប្រាស់
- ធ្វើឱ្យប្រសើរឡើងគុណភាពសេវាទូរគមនាគមន៍
- ជំរុញនិងលើកកម្ពស់ការប្រកួតប្រជែងដោយស្មោះត្រង់និងតម្លាភាព និង
- ចូលរួមកៀរគរចំណូលថវិកាជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះរាល់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងជំពូកទី៥ នៃអនុក្រឹត្យនេះ។

**មាត្រា៣ .-**

វាក្យសព្ទសំខាន់ៗ ត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សរសេរជាអក្សរកាត់ថា **ក.ប.ទ.** ជាស្ថាប័នមានសមត្ថកិច្ចលើការដឹកនាំនិងគ្រប់គ្រងការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ព្រមទាំងប្រមូលកម្រៃពីការចុះបញ្ជីនេះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៥ .-**

រាជរដ្ឋាភិបាលអាចជ្រើសរើសនិងផ្តល់សិទ្ធិដល់នីតិបុគ្គល ដើម្បីគ្រប់គ្រងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

## ជំពូកទី៣
## គោលការណ៍ទូទៅ

**មាត្រា៦ .-**

ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖

ក- ភាពត្រឹមត្រូវនៃអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

ខ- ការចុះបញ្ជីឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមជាកាតព្វកិច្ច លើកលែងតែឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមរបស់ទេសចរ ឬអ្នកដំណើរពីក្រៅប្រទេស ដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនលើសរយៈពេល ៦០ (ហុកសិប) ថ្ងៃ។

គ- ការហាមឃាត់ការក្លែងលេខអាយម៉ី។

## ជំពូកទី៤
## ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

**មាត្រា៧ .-**

ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមត្រូវបានបង្កើតឡើងដោយមានមុខងារនិងសមត្ថភាព ជាអាទិ៍៖

ក- គ្រប់គ្រងនិងផ្ទៀងផ្ទាត់សណ្ឋានភាពមុខងារប្រព័ន្ធ អ៊ី.អាយ.អ. ដែលដំណើរការដោយប្រតិបត្តិករទូរសព្ទចល័ត ស្របតាមបទប្បញ្ញត្តិជាធរមាន។

ខ- កត់ត្រាសកម្មភាពនៃប្រព័ន្ធ អ៊ី.អាយ.អ. របស់ប្រតិបត្តិករទូរសព្ទចល័ត។

គ- ផ្ទុផ្ទងនិងបំបែកលេខអាយម៉ីជាមួយ ឬចេញពីលេខមីសជិននិងលេខអ៊ីមស៊ី។

ឃ-កត់ត្រារាល់ការធ្វើបច្ចុប្បន្នកម្មនៃទិន្នន័យត្រីតាអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

ង- ស្វែងរកនិងកំណត់អត្តសញ្ញាណលេខអាយម៉ីត្រួតគ្នា នៅក្នុងបណ្តាញប្រតិបត្តិករទូរសព្ទចល័តនីមួយៗ ឬរវាងបណ្តាញរបស់ប្រតិបត្តិករទូរសព្ទចល័តផ្សេងគ្នា និងផ្អាកដំណើរការលេខអាយម៉ីដែលមិនត្រឹមត្រូវ។

ច- តភ្ជាប់នឹងប្រព័ន្ធពាក់ព័ន្ធផ្សេងទៀត ដើម្បីគាំទ្រដំណើរការរបស់ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

ឆ- ផ្អាកដំណើរការឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបាត់ឬក្លាយជាកម្មវត្ថុនៃចោរកម្ម និងដាក់ឱ្យដំណើរការឡើងវិញនូវឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលរកឃើញឬយកបានមកវិញ។

ជ- ផ្តល់មុខងារសម្រាប់ពិនិត្យនិងផ្ទៀងផ្ទាត់លេខអាយម៉ី តាមរយៈសារខ្លី យូ.អេស.អេស.ឌី កម្មវិធីទូរសព្ទចល័ត និងវេបសាយ។

ឈ-វិភាគនិងធ្វើរបាយការណ៍ពីទិន្នន័យពាក់ព័ន្ធលេខអាយម៉ី។

ញ-បំពេញមុខងារផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

**មាត្រា៨ .-**

ប្រតិបត្តិករទូរសព្ទចល័តត្រូវរៀបចំ គ្រប់គ្រង និងដំណើរការប្រព័ន្ធ អ៊ី.អាយ.អ. មួយ ដែលមានមុខងារនិងសមត្ថភាព ជាអាទិ៍៖

ក- កត់ត្រា ផ្ទុក និងផ្ទៀងផ្ទាត់ទិន្នន័យត្រីតាអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម របស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនីមួយៗ ព្រមទាំងបញ្ជូនទិន្នន័យទាំងនេះជាប្រចាំទៅប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដោយមានកូដនីយកម្ម។

ខ- ធ្វើសមកាលកម្មតាមពេលវេលាជាក់ស្តែងនូវបញ្ជីអនុញ្ញាត បញ្ជីអនុញ្ញាតមានលក្ខខណ្ឌ និងបញ្ជីផ្អាកដំណើរការ ជាមួយប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

គ- អនុញ្ញាតឬមិនអនុញ្ញាតឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមចូលទៅកាន់បណ្តាញរបស់ប្រតិបត្តិករទូរសព្ទចល័ត ផ្អែកលើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីអនុញ្ញាត បញ្ជីអនុញ្ញាតមានលក្ខខណ្ឌ និងបញ្ជីផ្អាកដំណើរការ។

ឃ-ផ្តល់ព័ត៌មានអំពីលេខអាយមីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមទៅអ្នកប្រើប្រាស់ដែលជាម្ចាស់តាមរយៈមធ្យោបាយ ជាអាទិ៍ សារខ្លីឬយូ.អេស.អេស.ឌី ដោយផ្អែកលើទិន្នន័យដែលប្រតិបត្តិករទូរសព្ទចល័តនីមួយៗបានរក្សាទុក។

ង- ធ្វើវិសិដ្ឋកម្មប្រព័ន្ធ អ៊ី.អាយ.អ. របស់ខ្លួន ទៅតាមការវិវត្តនៃបច្ចេកវិទ្យា ជាអាទិ៍ បច្ចេកវិទ្យាទូរសព្ទចល័តជំនាន់ទី៥ (5G)។

ច- ផ្តល់សេវាដែលមានគុណភាពល្អសម្រាប់គាំទ្រដល់ប្រតិបត្តិការទូរសព្ទចល័តក្នុងបណ្តាញរបស់ខ្លួន និងសហប្រតិបត្តិការជាមួយប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

**មាត្រា៩ .-**

**ក.ប.ទ.** និងប្រតិបត្តិករទូរសព្ទចល័ត ត្រូវរក្សាការពារទិន្នន័យក្នុងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម និងប្រព័ន្ធ អ៊ី.អាយ.អ. ឱ្យមានសុវត្ថិភាព និងរៀបចំប្រព័ន្ធការពារសន្តិសុខសាយប័រនៃប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម និងប្រព័ន្ធ អ៊ី.អាយ.អ. ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងសន្តិសុខឌីជីថល។

**មាត្រា១០ .-**

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនិងប្រព័ន្ធ អ៊ី.អាយ.អ. ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការតភ្ជាប់រវាងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ព្រមទាំងប្រព័ន្ធ អ៊ី.អាយ.អ. និងប្រភពទិន្នន័យផ្សេងទៀតរបស់ប្រតិបត្តិករទូរសព្ទចល័ត ព្រមទាំងលក្ខខណ្ឌនិងវិធានបច្ចេកទេសនានានៃប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនិងប្រព័ន្ធ អ៊ី.អាយ.អ. ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៥
## ប្រភេទឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

**មាត្រា១១ .-**

ប្រភេទឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលតម្រូវឱ្យចុះបញ្ជីក្នុងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម មានជាអាទិ៍៖

ក- ទូរសព្ទឆ្លាតដែលប្រើស៊ីម ឬអ៊ីស៊ីម។

ខ- ទូរសព្ទធម្មតាដែលប្រើស៊ីម។

គ- ទូរសព្ទអចល័តឥតខ្សែដែលប្រើស៊ីម។

ឃ-កុំព្យូទ័របន្ទះដែលប្រើស៊ីម។

ង- កុំព្យូទ័រប្រភេទភីឌីអេ។

ច- កុំព្យូទ័រ និងកុំព្យូទ័រយួរដៃដែលប្រើស៊ីម។

ឆ- ឧបករណ៍ដងហ្គោលដែលប្រើស៊ីម។

ជ- ម៉ូដឹមដែលប្រើស៊ីម។

ឈ-ឧបករណ៍ពោទ័រដែលប្រើស៊ីម។

ញ-សៀវភៅអេឡិចត្រូនិកដែលប្រើស៊ីម។

ដ- សម្ភារៈ ឬឧបករណ៍ផ្សេងទៀត ដែលកំណត់ដោយ **ក.ប.ទ.**។

ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលរៀបរាប់ខាងលើ ត្រូវអនុវត្តតាមជំពូកទី៦ នៃអនុក្រឹត្យនេះ។ ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមអាចធ្វើបន្ទាប់ពីការទទួលបានវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទនិងតែមប្រ៊ូប្រតិវេទន៍បច្ចេកទេស។

**មាត្រា១២ .-**

បញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមត្រូវចាត់ចំណាត់ថ្នាក់ ដូចខាងក្រោម៖

ក- **បញ្ជីអនុញ្ញាត** គឺជាបញ្ជីនៃលេខអាយម៉ីឬទិន្នន័យពាក់ព័ន្ធអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលត្រូវអនុញ្ញាតឱ្យតភ្ជាប់នឹងបណ្តាញទូរសព្ទចល័ត ជាអាទិ៍ ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបានចុះបញ្ជីស្របតាមជំពូកទី៦ នៃអនុក្រឹត្យនេះ។

ខ- **បញ្ជីអនុញ្ញាតមានលក្ខខណ្ឌ** គឺជាបញ្ជីនៃលេខអាយម៉ីឬទិន្នន័យពាក់ព័ន្ធអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលត្រូវអនុញ្ញាតឱ្យតភ្ជាប់នឹងបណ្តាញទូរសព្ទចល័ត តែមានជាប់លក្ខខណ្ឌក្នុងការប្រើប្រាស់ ជាអាទិ៍ ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលប្រើប្រាស់ដោយទេសចរ ឬអ្នកដំណើរពីក្រៅប្រទេស ដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនលើសរយៈពេល ៦០ (ហុកសិប) ថ្ងៃ។

គ- **បញ្ជីផ្អាកដំណើរការ** គឺជាបញ្ជីនៃលេខអាយម៉ីឬទិន្នន័យពាក់ព័ន្ធអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលមិនត្រូវអនុញ្ញាតឱ្យតភ្ជាប់នឹងបណ្តាញទូរសព្ទចល័ត ជាអាទិ៍ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលជាផលចោរកម្ម។

លក្ខខណ្ឌនៃការបញ្ចូលលេខអាយម៉ីឬទិន្នន័យពាក់ព័ន្ធអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមចូលទៅក្នុងបញ្ជីណាមួយខាងលើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៦

## ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

**មាត្រា១៣ .-**

ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលនាំចូលអាចចុះបញ្ជីបាន លុះត្រាតែត្រូវបានបញ្ជាក់ថាបានបង់ពន្ធនិងអាករនាំចូល ស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៤ .-**

បុគ្គលដែលទទួលបានវិញ្ញាបនបត្រទទួលស្គាល់គុណវុឌ្ឍិជាភ្នាក់ងារនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ពីនិយ័តករទូរគមនាគមន៍កម្ពុជា ត្រូវចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមមុននឹងចែកចាយនិងដាក់ឱ្យចរាចរនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៥.-**

បុគ្គលផលិតគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមមុននឹងចែកចាយនិងដាក់ឱ្យចរាចរនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១៦.-**

ម្ចាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលនាំចូលជាលក្ខណៈឯកជនដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ទើបអាចតភ្ជាប់នឹងបណ្តាញទូរសព្ទចល័តជាមួយប្រតិបត្តិករទូរសព្ទចល័តបាន។

**មាត្រា១៧.-**

បែបបទនិងនីតិវិធីនៃការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដូចមានចែងក្នុងជំពូកនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា១៨.-**

ប្រតិបត្តិករទូរសព្ទចល័តត្រូវផ្ទៀងផ្ទាត់លេខអាយមីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមជាមួយនឹងប្រព័ន្ធ អុី.អាយ.អ. របស់ខ្លួន មុននឹងអនុញ្ញាតឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមតភ្ជាប់នឹងបណ្តាញទូរសព្ទចល័តរបស់ខ្លួន។

ការផ្ទៀងផ្ទាត់លេខអាយមីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវបានលើកលែងចំពោះតែឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលប្រើប្រាស់សេវារ៉ូមីងពីក្រៅប្រទេស។

ការផ្ទៀងផ្ទាត់លេខអាយមីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវអនុលោមតាមស្តង់ដាប្រតិបត្តិការនិងលក្ខខណ្ឌបច្ចេកទេស ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៧
## ការផ្អាកដំណើរការនិងការដាក់ឱ្យដំណើរការឡើងវិញ នូវឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបាត់

**មាត្រា១៩.-**

ម្ចាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមអាចរាយការណ៍ និងស្នើសុំប្រតិបត្តិករទូរសព្ទចល័តឱ្យផ្អាកដំណើរការឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ក្នុងករណីមានការបាត់ដោយហេតុណាមួយ ជាអាទិ៍ អំពើចោរកម្មឬការបាត់ដោយខ្លួនឯង។ ក្នុងករណីរកឃើញឬយកបានឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនោះមកវិញ ម្ចាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមមានសិទ្ធិស្នើសុំប្រតិបត្តិករទូរសព្ទចល័តដាក់ឱ្យដំណើរការឡើងវិញនូវឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនោះ។

លក្ខខណ្ឌនិងនីតិវិធីនៃការរាយការណ៍អំពីឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបាត់ និងរកឃើញឬយកបានមកវិញ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

**មាត្រា២០.-**

ប្រតិបត្តិករទូរសព្ទចល័តត្រូវកត់ត្រាចំនួនឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបាត់ដោយហេតុណាមួយ ឬបានរកឃើញឬយកបានមកវិញ ទៅតាមបញ្ជីដែលបានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ និងត្រូវអនុវត្តតាម

សំណើរបស់ម្ចាស់ឧបករណ៍ដែលបានរាយការណ៍និងស្នើសុំប្រតិបត្តិករទូរសព្ទចល័តឱ្យផ្អាកដំណើរការឬដាក់ឱ្យដំណើរការឡើងវិញ ដោយអនុលោមតាមនីតិវិធីនិងលក្ខខណ្ឌបច្ចេកទេសនៃការផ្អាកដំណើរការឬការដាក់ឱ្យដំណើរការឡើងវិញនូវឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

## ជំពូកទី៨
## ការក្លែងលេខអាយម៉ី

**មាត្រា២១ .-**

អំពើក្លែងលេខអាយម៉ីត្រូវបានហាមឃាត់។ អំពើក្លែងលេខអាយម៉ី ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ការកម្ទេចឬបំប្លែងលេខអាយម៉ីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមណាមួយ ធ្វើឡើងដោយបុគ្គលក្រៅពីអ្នកផលិត ឬអ្នកទទួលសិទ្ធិស្របច្បាប់ពីអ្នកផលិតឧបករណ៍នោះ។

ខ- ការលួចចម្លងលេខអាយម៉ីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមមួយ ដាក់ឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមមួយទៀត។

គ- ការដំឡើងលេខអាយម៉ីឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមណាមួយ ដោយគ្មានការអនុញ្ញាត ឬដោយផ្ទុយពីលក្ខខណ្ឌ និងបែបបទដែលទទួលស្គាល់ពីសមាគមជីអេសអឹម។

ការហាមឃាត់ដូចបានកំណត់ក្នុងចំណុច ក និងចំណុច គ នៃកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវបានលើកលែងក្នុងគោលបំណងសិក្សាស្រាវជ្រាវនិងនវានុវត្តន៍ ដោយត្រូវមានការអនុញ្ញាតជាមុនពី **ក.ប.ទ.**។

**មាត្រា២២ .-**

ការផលិតនិងការកាន់កាប់សុសវែរសម្រាប់ក្លែងលេខអាយម៉ី ត្រូវបានហាមឃាត់។

ការផលិតនិងការកាន់កាប់ឧបករណ៍ឬសុសវែរដែលអាចប្រើប្រាស់សម្រាប់ក្លែងលេខអាយម៉ី ដោយមានចេតនាប្រើ ឬនាំឱ្យអ្នកដទៃប្រើឧបករណ៍ឬសុសវែរនោះ ដើម្បីក្លែងលេខអាយម៉ី ត្រូវបានហាមឃាត់។

ការលក់ ការចែកចាយ និងការធ្វើសំណើលក់ឬចែកចាយឧបករណ៍ឬសុសវែរដែលអាចប្រើប្រាស់សម្រាប់ក្លែងលេខអាយម៉ី ដោយដឹងឬជឿថាបុគ្គលដែលទទួលឬមានបំណងទទួល នឹងប្រើឧបករណ៍ឬសុសវែរនោះ ដើម្បីក្លែងលេខអាយម៉ី ត្រូវបានហាមឃាត់។

ការហាមឃាត់ដូចបានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃមាត្រានេះ ត្រូវបានលើកលែង ក្នុងគោលបំណងសិក្សាស្រាវជ្រាវនិងនវានុវត្តន៍ ដោយត្រូវមានការអនុញ្ញាតជាមុនពី **ក.ប.ទ.**។

## ជំពូកទី៩
## កម្រៃនៃការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម

**មាត្រា២៣ .-**

កម្រៃនៃការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី១០
## អធិការកិច្ច

**មាត្រា២៤ .-**

**ក.ប.ទ.** ត្រូវតាមដាននិងត្រួតពិនិត្យជាប្រចាំចំពោះការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។

ការធ្វើអធិការកិច្ចលើការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដូចមានចែងក្នុងជំពូកទី១៣ នៃច្បាប់ស្តីពីទូរគមនាគមន៍។

## ជំពូកទី១១
## ការដោះស្រាយវិវាទ

**មាត្រា២៥ .-**

ក្រៅពីករណីបទល្មើសព្រហ្មទណ្ឌ នៅពេលមានវិវាទពាក់ព័ន្ធនឹងការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ភាគីវិវាទត្រូវធ្វើការផ្សះផ្សាដោយសន្តិវិធី។

បែបបទនិងនីតិវិធីនៃការផ្សះផ្សាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី **ក.ប.ទ.**។

ករណីពុំមានការសះជា ភាគីវិវាទអាចបន្តនីតិវិធីទៅមជ្ឈត្តការឬតុលាការមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា២៦ .-**

ការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដូចខាងក្រោម ទៅក្នុងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវកំណត់ដោយឡែកដោយ **ក.ប.ទ.**៖

ក- ឧបករណ៍អ៊ីនធឺណិតនៃវត្ថុដែលប្រើស៊ីម។

ខ- ឧបករណ៍ជីភីអេសដែលប្រើស៊ីម។

គ- សម្ភារៈបំពាក់តាមខ្លួនដែលប្រើស៊ីម។

ឃ-យានជំនិះដែលប្រើស៊ីម។

## ជំពូកទី១៣
## ទោសប្បញ្ញត្តិ

**មាត្រា២៧ .-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះរួមមាន ទណ្ឌកម្មរដ្ឋបាល និងពិន័យអន្តរការណ៍។

ទណ្ឌកម្មរដ្ឋបាល រួមមាន៖

ក- ការដាក់កំហិតលើអាជ្ញាបណ្ណ លិខិតអនុញ្ញាត និង/ឬវិញ្ញាបនបត្រ។

ខ- ការព្យួរអាជ្ញាបណ្ណ លិខិតអនុញ្ញាត និង/ឬវិញ្ញាបនបត្រ។

គ- ការដកហូតអាជ្ញាបណ្ណ លិខិតអនុញ្ញាត និង/ឬវិញ្ញាបនបត្រ។

ឃ-វិធានការរដ្ឋបាលផ្សេងទៀតតាមការចាំបាច់ ស្របតាមការកំណត់ដោយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ការសម្រេចដាក់ទណ្ឌកម្មរដ្ឋបាល ត្រូវអនុវត្តស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការសម្រេចដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ការបង់ប្រាក់ពិន័យអន្តរការណ៍មិននាំឱ្យរួចផុតពីកាតព្វកិច្ចអនុវត្តវិធានការរដ្ឋបាល និងទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលបានដាក់ចេញស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះនិងបទប្បញ្ញត្តិជាធរមាន។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បែបបទនិងនីតិវិធីនៃការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការបង់ប្រាក់ពិន័យអន្តរការណ៍ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យអន្តរការណ៍ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យអន្តរការណ៍ចំពោះអំពើល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រី **ក.ប.ទ.** និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៨ .-**

ក្នុងករណីពិនិត្យឃើញថា បុគ្គលណាមួយបំពានបទប្បញ្ញត្តិក្នុងមាត្រា៨ មាត្រា៩ មាត្រា១៤ មាត្រា១៥ កថាខណ្ឌទី១ នៃមាត្រា១៨ មាត្រា២០ មាត្រា២១ ឬមាត្រា២២ នៃអនុក្រឹត្យនេះ ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត **ក.ប.ទ.** ត្រូវណែនាំឱ្យកែតម្រូវ។ ក្នុងករណីបុគ្គលនោះមិនបានធ្វើការកែតម្រូវតាមការណែនាំ បុគ្គលនោះត្រូវទទួលទណ្ឌកម្ម ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា២៩ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះប្រតិបត្តិករទូរសព្ទចល័តដែលមិនបានរៀបចំ គ្រប់គ្រង និងដំណើរការប្រព័ន្ធ អ៊ី.អាយ.អ. មួយដែលមានមុខងារនិងសមត្ថភាព ដូចមានចែងក្នុងមាត្រា៨ នៃអនុក្រឹត្យនេះ។

**មាត្រា៣០ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះប្រតិបត្តិករទូរសព្ទចល័តដែលមិនបានរក្សាការពារទិន្នន័យក្នុងប្រព័ន្ធ អ៊ី.អាយ.អ. ឱ្យមានសុវត្ថិភាពនិងរៀបចំប្រព័ន្ធការពារសន្តិសុខសាយប័រនៃប្រព័ន្ធ អ៊ី.អាយ.អ. ដូចមានចែងក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ។

**មាត្រា៣១ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះភ្នាក់ងារនាំចូលគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលមិនបានចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដូចមានចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យនេះ។

**មាត្រា៣២ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះអ្នកផលិតគ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍ ដែលមិនបានចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ដូចមានចែងក្នុងមាត្រា១៥ នៃអនុក្រឹត្យនេះ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៥០០ ០០០ ០០០ (ប្រាំរយលាន) រៀល ចំពោះនីតិបុគ្គល ដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា៣៣ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ចំពោះប្រតិបត្តិករទូរសព្ទចល័តដែលមិនអនុវត្តកាតព្វកិច្ចណាមួយ ដូចខាងក្រោម៖

ក- ការមិនបានកត់ត្រាចំនួនឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបាត់ដោយហេតុណាមួយ ឬបានរកឃើញ ឬយកបានមកវិញ ដូចមានចែងក្នុងមាត្រា២០ នៃអនុក្រឹត្យនេះ។

ខ- ការមិនអនុវត្តតាមសំណើរបស់ម្ចាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលបានរាយការណ៍ និងស្នើសុំប្រតិបត្តិករទូរសព្ទចល័តឱ្យផ្អាកដំណើរការឬដាក់ឱ្យដំណើរការឡើងវិញ ដូចមានចែងក្នុងមាត្រា១៩ នៃអនុក្រឹត្យនេះ។

**មាត្រា៣៤ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះប្រតិបត្តិករទូរសព្ទចល័តដែលមិនបានផ្ទៀងផ្ទាត់លេខអាយម៉ីរបស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមជាមួយនឹងប្រព័ន្ធ អ៊ី.អាយ.អ. មុននឹងអនុញ្ញាតឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមតភ្ជាប់នឹងបណ្តាញទូរសព្ទចល័តរបស់ខ្លួន ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា៣៥ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះបុគ្គលដែលប្រព្រឹត្តអំពើក្លែងលេខអាយម៉ី ដូចមានចែងក្នុងមាត្រា២១ នៃអនុក្រឹត្យនេះ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ៤ ០០០ ០០០ (បួនលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះនីតិបុគ្គល ដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា៣៦ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល ចំពោះបុគ្គលដែលផលិតឬកាន់កាប់សុសវែរសម្រាប់ក្លែងលេខអាយម៉ី ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា២២ នៃអនុក្រឹត្យនេះ ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២០០ ០០០ ០០០ (ពីររយលាន) រៀល ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

**មាត្រា៣៧ .-**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះបុគ្គលដែលផលិតឬកាន់កាប់ឧបករណ៍ឬសុសវែរដែលអាចប្រើប្រាស់សម្រាប់ក្លែងលេខអាយម៉ី ដោយមានចេតនាប្រើឬ

នាំឱ្យអ្នកដទៃប្រើឧបករណ៍ឬសុសវែរនោះ ដើម្បីក្លែងលេខអាយមុី ដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រា២២ នៃអនុក្រឹត្យនេះ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះបុគ្គលដែលលក់ ចែកចាយ ឬធ្វើសំណើលក់ឬចែកចាយឧបករណ៍ឬសុសវែរដែលអាចប្រើប្រាស់សម្រាប់ក្លែងលេខអាយមុី ដោយដឹងឬជឿថាបុគ្គលដែលទទួលឬមានបំណងទទួលនឹងប្រើឧបករណ៍ឬសុសវែរនោះ ដើម្បីក្លែងលេខអាយមុី ដូចមានចែងក្នុងកថាខណ្ឌទី៣ នៃមាត្រា២២ នៃអនុក្រឹត្យនេះ។

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល ក្នុងឧបករណ៍១គ្រឿង ចំពោះនីតិបុគ្គលដែលប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២ នៃមាត្រានេះ។

**មាត្រា៣៨ .-**

បុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ពិន័យអន្តរការណ៍ ដូចមានចែងពីមាត្រា២៩ ដល់មាត្រា៣៦ នៃអនុក្រឹត្យនេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តអំពើល្មើសដដែលម្តងទៀត ប្រាក់ពិន័យអន្តរការណ៍ត្រូវកើនឡើងទ្វេដង។

**មាត្រា៣៩ .-**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី១៣ នៃអនុក្រឹត្យនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌផ្សេងទៀតក្នុងករណីដែលអំពើដែលបានកំណត់ថាជាអំពើល្មើសដែលមានចែងក្នុងអនុក្រឹត្យនេះ ជាអំពើល្មើសដែលបានបញ្ញត្តក្នុងច្បាប់និងបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី១៤
## អន្តរប្បញ្ញត្តិ

**មាត្រា៤០ .-**

ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលកំពុងតភ្ជាប់នឹងបណ្តាញទូរសព្ទចល័ត ត្រឹមថ្ងៃដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម នឹងត្រូវបានចុះបញ្ជីលេខអាយមុីជាស្វ័យប្រវត្តិ ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ។

**មាត្រា៤១ .-**

ម្ចាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលមានពីមុន ហើយមិនបានតភ្ជាប់នឹងបណ្តាញទូរសព្ទចល័ត ត្រឹមថ្ងៃដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ត្រូវស្នើសុំចុះបញ្ជីលេខអាយមុីរបស់ឧបករណ៍នោះ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ ដោយឥតបង់ថ្លៃ គិតចាប់ពីថ្ងៃដាក់ឱ្យដំណើរការប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ស្របតាមនីតិវិធីដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ។

## ជំពូកទី១៥
## អវសានប្បញ្ញត្តិ

**មាត្រា៤២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ** ៤១ **អនក្រ.បក ចុះថ្ងៃទី** ៣ **ខែ** កុម្ភៈ **ឆ្នាំ២០២៣**
**ស្តីពីការចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម**

**សន្ទានុក្រម**

| | | |
|---|---|---|
| ១. | កុំព្យូទ័រប្រភេទភីឌីអេ<br>PDA - Personal Digital Assistants | សំដៅដល់ឧបករណ៍ចល័ត ដែលផ្តល់សមត្ថភាពក្នុងការផ្ទុកទិន្នន័យ និងមុខងារកុំព្យូទ័រ ទាញយកទិន្នន័យផ្សេងៗ សម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន។ ជាទូទៅ កុំព្យូទ័រប្រភេទភីឌីអេ ប្រើសម្រាប់រក្សាកាលវិភាគប្រតិទិន និងព័ត៌មានសៀវភៅអាសយដ្ឋាន ជាដើម។ |
| ២. | ទិន្នន័យត្រីតាអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម<br>Triplet Data | សំដៅដល់សំណុំលេខអាយមុី (IMEI) លេខអុីមសុី (IMSI) និងលេខមីសឌិន (MSISDN)។ |
| ៣. | ធ្វើវិសិដ្ឋកម្ម<br>Upgrade | សំដៅដល់ការធ្វើឱ្យប្រសើរឡើងនូវមុខងារកុំព្យូទ័រ ម៉ាស៊ីន ឬផ្នែកខ្លះនៃកម្មវិធីសុសវែរ ដើម្បីផ្តល់លទ្ធភាពសម្រាប់ធ្វើអ្វីៗបានច្រើនទៀត។ |
| ៤. | ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម<br>EIRS - Equipment Identity Registration System | សំដៅដល់ប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមជាតិ (National Equipment Identity Registration System - National EIRS) ដែលមុខងារគ្រប់គ្រងនិងធ្វើឯកសណ្ឋានភាពជាមួយប្រព័ន្ធ អុី.អាយ.អ. ដែលដំណើរការដោយប្រតិបត្តិករទូរសព្ទចល័តស្របតាមបទប្បញ្ញត្តិជាធរមាន។ |
| ៥. | ប្រព័ន្ធអុី.អាយ.អ<br>EIR - Equipment Identity Register | សំដៅដល់ប្រព័ន្ធដែលត្រូវដំឡើងនិងដំណើរការដោយប្រតិបត្តិករទូរសព្ទចល័ត និងត្រូវភ្ជាប់ជាមួយនឹងប្រព័ន្ធចុះបញ្ជីអត្តសញ្ញាណឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម។ ប្រព័ន្ធអុី.អាយ.អ មានមុខងារអនុញ្ញាតឬមិនអនុញ្ញាតឱ្យឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមចូលទៅកាន់បណ្តាញរបស់ប្រតិបត្តិករទូរសព្ទចល័ត ផ្អែកលើការផ្ទៀងផ្ទាត់ជាមួយនឹងបញ្ជីអនុញ្ញាត បញ្ជីអនុញ្ញាតមានលក្ខខណ្ឌនិងបញ្ជីផ្អាកដំណើរការ។ |
| ៦. | យូ.អេស.អេស.ឌី<br>USSD - Unstructured Supplementary Service Data | សំដៅដល់សេវាទំនាក់ទំនងមួយដែលប្រើក្នុងបណ្តាញ GSM សម្រាប់ការផ្ញើសារខ្លីៗ មានទម្រង់ស្រដៀងនឹងសារខ្លី (SMS) ដែរ។ ទោះយ៉ាងណាក៏ដោយ យូ.អេស.អេស.ឌី គឺជាសេវាកម្មផ្ញើសារខ្លីភ្លាមៗ ដោយមិនត្រូវបានរក្សាទុកសារខ្លីនោះ នៅខាងបណ្តាញប្រតិបត្តិករឬនៅលើឧបករណ៍របស់អ្នកប្រើប្រាស់ទេ។ |

| | | |
|---|---|---|
| ៧. | លេខមីសឌីន<br>MSISDN - Mobile Subscriber Integrated Services Digital Network Number | សំដៅដល់លេខសម្គាល់ការចុះឈ្មោះប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីម ក្នុងបណ្តាញប្រព័ន្ធទូរសព្ទចល័តសកល ( Global System for Mobile Communication )។ លេខមីសឌីនមានរហូតដល់ ១៥ ( ដប់ប្រាំ ) ខ្ទង់ដែលចែកចេញជាទម្រង់ដូចខាងក្រោម៖<br>- ពី ១ (មួយ) ទៅ ៣ (បី) ខ្ទង់ សម្គាល់លេខកូដប្រទេស<br>- លេខកូដបន្តបន្ទាប់ត្រូវបានកំណត់ជាលេខកូដសម្គាល់គោលដៅក្នុងប្រទេស ( National Destination Code ) និងលេខកូដសម្គាល់អ្នកប្រើប្រាស់ ( Subscript Numbers )។ |
| ៨. | លេខអាយមី<br>IMEI - International Mobile Equipment Identity | សំដៅដល់លេខសម្គាល់ជាអន្តរជាតិសម្រាប់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមដែលមានចំនួន ១៥ ( ដប់ប្រាំ ) ខ្ទង់ ចែកចេញជាទម្រង់ដូចខាងក្រោម៖<br>- លេខ ៨ ( ប្រាំបី ) ខ្ទង់ដំបូង ហៅថា លេខកូដសម្គាល់យថាប្រភេទឧបករណ៍ (Type Allocation Code - TAC )<br>- លេខ ៦ (ប្រាំមួយ) បន្ទាប់ ហៅថា លេខរៀងឧបករណ៍ (Digit Serial Numbers - SNR )<br>- លេខ ១ (មួយ) ខ្ទង់ចុងក្រោយ ត្រូវប្រើប្រាស់សម្រាប់ត្រួតពិនិត្យខ្ទង់លេខដែលប្រើសម្រាប់អាយមី មានពីលេខ ០ ដល់លេខ ៩។ |
| ៩. | លេខអ៊ីមស៊ី<br>IMSI - International Mobile Subscriber Identity | សំដៅដល់ស៊េរីនៃលេខដែលមានលេខកូដអន្តរជាតិ ១៥ (ដប់ប្រាំ) ខ្ទង់ ឬតិចជាងនេះ ដែលប្រើដើម្បីកំណត់អត្តសញ្ញាណអ្នកប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍ប្រើស៊ីមនៅក្នុងបណ្តាញនៃប្រព័ន្ធសកលសម្រាប់ប្រព័ន្ធទំនាក់ទំនងទូរសព្ទចល័ត ដែលចែកចេញជាទម្រង់ដូចខាងក្រោម៖<br>- លេខ ៣ (បី) ខ្ទង់ដំបូង ជាលេខសម្គាល់លេខកូដប្រទេស ( MCC - Mobile Country Code )<br>- លេខ ២ (ពីរ) ខ្ទង់បន្ទាប់ ជាលេខសម្គាល់លេខកូដក្នុងបណ្តាញប្រតិបត្តិករទូរសព្ទចល័ត ( MNC - Mobile Network Code )<br>- ខ្ទង់លេខដែលនៅសល់ ជាលេខសម្គាល់លេខទូរសព្ទរបស់អ្នកប្រើប្រាស់ក្នុងប្រទេស ( Mobile Suscription Identification Numbers )។ |
| ១០. | សមកាលកម្មតាមពេលវេលាជាក់ស្តែង<br>Synchronization in Real-Time | សំដៅដល់សមត្ថភាពដែលអាចធ្វើបច្ចុប្បន្នភាពបានយ៉ាងលឿននូវការផ្លាស់ប្តូរចុងក្រោយបំផុតដោយប្រព័ន្ធកណ្តាលរួមមួយ។ ជាទូទៅ វាមានមុខងារត្រួតពិនិត្យថតឯកសារទាំងឡាយដែលមានឯកសារ |

| | |
|---|---|
| | បានផ្លាស់ប្តូរ ចម្លងថ្មី ឬឯកសារបានកែប្រែ ដោយប្រើរយៈពេលពន្យារយ៉ាងខ្លីបំផុតក្នុងការធ្វើបច្ចុប្បន្នកម្មទៅបណ្តាញតភ្ជាប់ដទៃទៀត បន្ទាប់ពីការផ្លាស់ប្តូរ ទាំងនោះបានកើតឡើង។ |
| ១១. សមាគមជីអេសអឹម<br>GSMA - GSM Association | សំដៅដល់សមាគមអន្តរជាតិនៃប្រតិបត្តិករទូរសព្ទចល័តនិងភាគីពាក់ព័ន្ធដែលទទួលខុសត្រូវបែងចែកកូដ TAC ដែលត្រូវប្រើប្រាស់សម្រាប់បង្កើតអត្តសញ្ញាណហាដវែរចល័តអន្តរជាតិ។ សមាគមនេះធ្វើការបែងចែកលំដាប់ផ្លូវការនៃលេខ TAC ទៅរាល់អ្នកដំឡើងឧបករណ៍ទាំងអស់ ដែលអាចប្រើប្រាស់បានជាមួយ 3GPP និងកត់ត្រារាល់លំដាប់ទាំងនេះនិងទិន្នន័យម៉ូដែលឧបករណ៍ទៅក្នុងមូលទិន្នន័យ។ ផ្អែកលើមូលទិន្នន័យនេះ គឺនឹងអនុញ្ញាតឱ្យអង្គភាពដែលទទួលសិទ្ធិក្នុងការស្វែងរកនិងការកំណត់អត្តសញ្ញាណ អាចកំណត់អត្តសញ្ញាណអ្នកដំឡើងឧបករណ៍និងម៉ូដែលបានច្បាស់លាស់ តាមរយៈលេខអាយម៉ី។ |
| ១២. សេវារ៉ូមីងពីក្រៅប្រទេស<br>Inbound Roaming | សំដៅដល់សេវារ៉ូមីងទូរសព្ទចល័តអន្តរជាតិ ដែលប្រើប្រាស់បណ្តាញរបស់ប្រតិបត្តិករទូរសព្ទចល័តរបស់ព្រះរាជាណាចក្រកម្ពុជា។ |
| ១៣. ស៊ីម<br>SIM - Subscriber Identity Module | សំដៅដល់ស៊ីមកាត ឬអ៊ីស៊ីម។ |
| ១៤. ស្រ៊ីជីភីភី<br>3GPP - The 3rd Generation Partnership Project | សំដៅដល់បណ្តុំអង្គការចំនួនប្រាំពីរ (មានជាអាទិ៍ ARIB, ATIS, CCSA, ETSI, TSDSI, TTA, TTC) ដែលអភិវឌ្ឍស្តង់ដារទូរគមនាគមន៍ ហើយផ្តល់ឱ្យសមាជិករបស់ខ្លួននូវបរិស្ថានប្រកបដោយស្ថិរភាពមួយសម្រាប់បោះពុម្ពផ្សាយរបាយការណ៍និងការបញ្ជាក់បច្ចេកទេស (Specifications) ដែលកំណត់អំពីបច្ចេកវិទ្យាស្រ៊ីជីភីភី។ |
| ១៥. ឧបករណ៍ដងហ្គោលដែលប្រើស៊ីម<br>Dongle with SIM modules | សំដៅដល់ឧបករណ៍ចល័ត ដែលអាចតភ្ជាប់ជាមួយកុំព្យូទ័រយួរដៃ ឬកុំព្យូទ័រផ្សេងទៀត តាមរយៈច្រក USB ឬច្រកផ្សេងទៀត ដើម្បីផ្តល់សេវាអ៊ីនធឺណិត តាមរយៈបណ្តាញទូរគមនាគមន៍ចល័ត។ |
| ១៦. ឧបករណ៍រ៉ោទ័រដែលប្រើស៊ីម<br>WLAN routers with SIM modules | សំដៅដល់ឧបករណ៍ចល័ត ដែលមានមុខងារផ្តល់សេវាអ៊ីនធឺណិតទៅឱ្យឧបករណ៍ផ្សេងទៀត តាមរយៈបណ្តាញទូរគមនាគមន៍ចល័ត។ |